00702574

នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

E51/11/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 06 / 06 / 2011
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជជ |
| ភាគីដាក់ឯកសារ៖ | សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី |
| ដាក់ជូន៖ | **អង្គជំនុំជម្រះសាលាដំបូង** |
| ភាសាដើម៖ | ខ្មែរ(បកប្រែបារាំង) |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០១១ |

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖ **សាធារណៈ / Public**

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ចម្លើយតបចំពោះសារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញត្រកម្មបឋមតាមទិដ្ឋភាព៨៩**
**(គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ)**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ៖**

ពេជ អង្គ
Elisabeth SIMONNEAU-FORT

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ៖**

ម៉ុច សុវណ្ណារី
គីម ម៉េងឃី
ជេត វណ្ណលី
ហុង គីមសួន
ឡោ ជុនធី
ស៊ិន សុវ៉ន

**ដាក់ជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ អុត្តារ៉ា

**ចំលងជូន ៖**

**សហព្រះរាជអាជ្ញា ៖**

ជា លាង
Andrew CAYLEY

សំ សុគង់

វ៉ែន ពៅ

ទី ស្រ៊ីនណា

Silke STUDZINSKY
Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Madhev MOHAN
Barnabé NEKUIE
Lyma Thuy NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI

យ៉េត ចរិយា

William SMITH

<u>ជនជាប់ចោទ</u>

អៀង សារី

**សហមេធាវីការពារក្តីជនជាប់ចោទ**

អាង ឧត្តម

Michael G.KARNAVAS

## I. រំលឹកអង្គហេតុនិងនីតិវិធី

១. នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តីលោកអៀង សារី បានដាក់សារណាលើអញ្ញាត្រកម្មបឋមចំនួនពីរ ដែលសារណាទីមួយ ទាក់ទងនឹងអាជ្ញាយុកាលលើអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[1] និងសារណាទីពីរ ជាបណ្តឹងលើអញ្ញាត្រកម្មបឋម អនុលោមតាមវិធាន៨៩(១)(គ)[2]។

២. នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ លោក អៀង សារី បានដាក់សេចក្តីសង្ខេបនៃអញ្ញាត្រកម្មបឋមរបស់ខ្លួន[3]។

៣. នៅថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១១ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ចម្លើយតបរួមរបស់ខ្លួនទៅលើបណ្តឹងអញ្ញាត្រកម្មដែលបានលើកឡើងដោយជនជាប់ចោទទាំងបួន[4]។

៤. នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង (អ.ជ.ដ) បានចេញសេចក្តីណែនាំអនុញ្ញាត្តិឲ្យ ក្រុមមេធាវីការពារក្តី លោកអៀង សារី ដាក់អញ្ញាត្រកម្មបន្ថែមស្តីពី គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ[5]។

៥. នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តីបានដាក់សារណាបន្ថែមរបស់ខ្លួនលើអញ្ញាត្រកម្មទាក់ទងនឹងគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ ដែលសារណានេះត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១ (សារណាបន្ថែម)[6]។

---

[1] ឯកសារលេខ E43 សារណារបស់ អៀង សារី ស្តីពីអញ្ញត្រកម្មបឋម អនុឡោមតាមវិធាន ៨៩ (អាជ្ញាយុកាលសម្រាប់អំពើបំពាន) ចុះថ្ងៃទី១៤ កុម្ភៈ ២០១១ ។

[2] ឯកសារលេខ E48 សារណារបស់ អៀង សារី អនុឡោមតាមវិធាន ៨៩ (១)(គ) ចុះថ្ងៃទី១៤ កុម្ភៈ ២០១១។

[3] ឯកសារលេខ E51/4 សេចក្តីសង្ខេបនៃសារណារបស់ អៀង សារី ស្តីពីអញ្ញត្រកម្មបឋម អនុឡោមតាមវិធាន ៨៩ ចុះថ្ងៃទី២៥ កុម្ភៈ ២០១១។

[4] ចម្លើយតបរួមរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងអញ្ញត្រកម្មរបស់ជនជាប់ចោទទាំង៤ ឯកសារ E51/5/4។

[5] ឯកសារលេខ E51/9

[6] សារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញាត្រកម្មអនុលោមតាមវិធាន៨៩ (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះ បទល្មើសតែមួយ (ne bis in idem)) ឯកសារលេខ E51/11។

00702577



៦. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពិចារណាឃើញថា កាលបរិច្ឆេទចុងក្រោយដែល អ.ជ.ជ បានផ្តល់ឱ្យភាគីធ្វើការឆ្លើយសារណាបន្ថែមរបស់ អៀង សារី គឺមិនអាចអនុវត្តបានទេ ដោយយោងទៅលើស្ថានភាពបច្ចុប្បន្ននៃការរៀបចំការតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមរំលឹកថា យោងតាមវិធាន ១២ ស្ទួនពីរ (៣) កាតព្វកិច្ចចំបងរបស់ពួកគាត់គឺត្រូវពិគ្រោះយោបល់ជាមួយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវប្រឹងប្រែងធ្វើយ៉ាងណាឱ្យមានការយល់ព្រមជាឯកច្ឆ័ន្ទដើម្បីសម្របសម្រួលការតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធី។ ការសម្របសម្រួលនេះ (សម្រាប់មេធាវីលើសពី៣០នាក់) ធ្វើការជា៣ភាសាផ្លូវការរបស់តុលាការដែលមេធាវីទាំងអស់នេះមកពីប្រទេសដែលអនុវត្តប្រព័ន្ធច្បាប់ខុសៗគ្នា គឺមិនអាចអនុវត្តទៅរួចទេនៅក្នុងរយៈពេលត្រឹមតែ ០៦ ថ្ងៃ ដោយរាប់បញ្ចូលទាំងថ្ងៃចុងសប្តាហ៍ផងនោះ។

៧. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យ អ.ជ.ជ ធ្វើការពិចារណាទៅលើបញ្ហាលំបាកដែលបានរៀបរាប់ខាងលើ ហើយធ្វើការពិចារណាទៅលើសារណាខាងក្រោមនេះ ដែលត្រូវបានសរសេរឡើងដោយក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុម។

## II. សេចក្តីផ្តើម

៨. ក្រុមមេធាវីការពារក្តី លោក អៀង សារី បានលើកឡើងនៅក្នុងទឡ្ហីករណ៍របស់ខ្លួនថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)មិនមានយុត្តាធិការទៅលើរូបលោកអៀងសារីឡើយ អនុលោមតាមការអនុវត្តគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ការហាមឃាត់នូវការអនុវត្តន៍ ការចោទប្រកាន់ច្រើនបទចោទចំពោះអំពើរល្មើសដូចគ្នា - prohibition against multiple prosecutions for the same offence[7]) ដោយអះអាងថា (១) អង្គបុរេជំនុំជម្រះ (អ.ប.ជ) មានការភន្តច្រឡំនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[8]។ ក្រុមមេធាវីការពារក្តីបានព្យាយាមបង្ហាញថា អ.ប.ជ មានការភន្តច្រឡំផ្លូវច្បាប់ក្នុងការសម្រេចថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងកតិកាសញ្ញា

---

[7] ឯកសារលេខ C22/I/26, D390/1/2.3, D427/1/6 និង D427/1/23

[8] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារលេខ D427/1/30។

អន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) មិនរារាំងការចោទប្រកាន់លោក អៀង សារី នាពេលបច្ចុប្បន្ននេះទេ និង(២) បញ្ហាថាតើការជំនុំជម្រះកាលពីឆ្នាំ១៩៧៩ របស់តុលាការបដិវត្តន៍ប្រជាជន ធ្វើឡើងស្របតាមបទដ្ឋានត្រឹមត្រូវដែរឬទេ រួមទាំងក្របខណ្ឌគតិយុត្តិដែលតុលាការនេះលើកយកមកធ្វើជាបង្អែកផងដែរ នោះមិនចាំបាច់ត្រូវឆ្លើយទេ ពីព្រោះទោះបីជាការជម្រះក្តីក្នុងឆ្នាំ១៩៧៩ មិនត្រូវបានប្រព្រឹត្តិទៅដោយអនុលោមតាមបទដ្ឋានត្រឹមត្រូវក៏ដោយ ក៏វាមិនមានករណីលើកលែងណាមួយក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងកតិកាសញ្ញា ICCPR ដែលនឹងអនុញ្ញាតឱ្យមានការចោទប្រកាន់ នាពេលបច្ចុប្បន្ននេះ[9]។

៩. អនុលោមតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមធ្វើការឆ្លើយតបចំពោះសារណាបន្ថែមលើអញ្ញត្រកម្មបឋមនេះ។

## III. ការពិភាក្សា

១០. នៅក្នុងចម្លើយតបនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងលើកទឡ្ហីករណ៍បន្ថែម ទៅលើអំណះអំណាងដែលខ្លួនបានលើកកន្លងមកហើយ ទាក់ទងនឹងប្រធានបទនេះ[10] ដូចខាង ក្រោម៖

១១. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមលើកជាចំបងថា ទឡ្ហីករណ៍ទាំងឡាយដែលត្រូវបានលើកឡើង ក្នុងសារណាបន្ថែមរបស់ក្រុមមេធាវីការពារក្តីនេះ មិនគួរត្រូវបានលើកយកមកពិចារណាឡើយ ដោយមូលហេតុថាទឡ្ហីករណ៍ទាំងនេះជាការលើកឡើងច្រំដែល មិនមែនជាទឡ្ហីករណ៍ថ្មី និងជាអំណះអំណាងដែលមិនបានឆ្លើយតបទៅនឹងការចង្អុលបង្ហាញរបស់ អ.ជ.ជ ឡើយ។

១២. ក្នុងករណីដែល អ.ជ.ជ សម្រេចថាគួរពិចារណាលើសារណាបន្ថែមនេះ មេធាវីដើមបណ្តឹងរដ្ឋប្ប

[9] ឯកសារលេខ E51/11 កថាខណ្ឌទី២៩។

[10] សូមមើលផងដែរនូវចម្លើយរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឯកសារលេខ C22/I/35 កថាខណ្ឌ១៣ ដល់ ២៨ និង ចម្លើយតបរួមរបស់ក្រុមមេធាវីគ្មានព្រំដែនទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិត និងខៀវ ជា ប្រឆាំងនឹងដីកា ដំណោះស្រាយ ឯកសារលេខ D427/1/18 កថាខណ្ឌ ៦៣ ដល់ ៦៥។

វេណីសូមធ្វើការឆ្លើយតបទៅលើទឡ្ហីករណ៍នីមួយៗក្នុងន័យបង្ហាញថា អំណះអំណាងទាំងនេះគួរត្រូវបានច្រានចោលដោយ អ.ប.ជ ដោយមូលហេតុមិនត្រឹមត្រូវតាមគតិច្បាប់។

**ក. អំណះអំណាងទីមួយ (មូលដ្ឋានចម្បង) ភាពមិនអាចឧទ្ធលបាននៃសារណាបន្ថែមៈ**

១៣. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ប្រសិនបើក្រុមមេធាវីការពារក្តី អៀង សារី មានបំណងចង់ដាក់សារណាបន្ថែមលើអញ្ញត្រកម្មទាក់ទងនឹងគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ លោកគួរកំណត់សារណាបន្ថែមរបស់ខ្លួនត្រឹមបញ្ហាថាតើមេធាវីការពារក្តីយល់ថា ការជំនុំជម្រះកាលពីឆ្នាំ១៩៧៩ របស់តុលាការបដិវត្តន៍ប្រជាជនធ្វើឡើងស្របតាមបទដ្ឋានត្រឹមត្រូវដែរឬទេ រួមទាំងក្របខណ្ឌគតិយុត្តិដែលតុលាការនេះ លើកយកមកធ្វើជាបង្អែកផងដែរ។ អង្គជំនុំជម្រះសាលាដំបូងបានកំហិតសារណាបន្ថែមនេះត្រឹមតែជាការលើកឡើងនូវសាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ជំទាស់នឹងដីកាដំណោះស្រាយចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ (ឯកសារលេខ D427/1/30) *ប្រសិនបើសាលដីកានោះនាំមកនូវទឡ្ហីករណ៍ថ្មីៗថែមទៀត*[11]។

១៤. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រទៅលើអំណះអំណាងរបស់ អ.ប.ជ ទាក់ទងនឹងសារៈសំខាន់ និងការអនុវត្តគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយនៅក្នុងបរិបទ អ.វ.ត.ក[12]។

១៥. បទប្បញ្ញត្តិនៃវិធាន៧៧(១៣)នៃវិធានផ្ទៃក្នុងបានចែងថា រាល់សេចក្តីសម្រេចដែលចេញដោយអង្គបុរេជំនុំជម្រះជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ហើយអង្គជំនុំជម្រះសាលាដំបូងមិនមែនជាអង្គជំនុំជម្រះថ្នាក់ទីពីរដែលមានយុត្តាធិការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលដីការបស់ អ.ប.ជ ទេ ដូចដែលមេធាវីការពារក្តីបានលើកឡើងនោះទេ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនធ្វើការបដិសេធទៅលើសិទ្ធិរបស់ភាគីក្នុងការដាក់អញ្ញត្រកម្មបឋមនៅចំពោះមុខអង្គជំនុំជម្រះទេ ប៉ុន្តែ

យើងខ្ញុំសូមធ្វើការក្រើនរំលឹកថា ការដាក់អញ្ញត្រកម្មបន្ថែមត្រូវបង្ហាញអំណះអំណាងថ្មី។

---

[11] ឯកសារលេខ E51/9 ។

[12] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារលេខ D427/1/30 កថាខណ្ឌ១១៨ ដល់ ១៧៦។

១៦. ជាចុងក្រោយ ប្រសិនបើយើងក្រឡេកមើលទៅលើអំណះអំណាងរបស់មេធាវីការពារក្តីទាក់ទងទៅនឹងការជម្រះក្តីក្នុងឆ្នាំ១៩៧៩ យើងឃើញថា មេធាវីការពារក្តីមិនបានឆ្លើយតបទៅនឹងសំណួររបស់ អ.ប.ជ ទេ[13]។

១៧. សរុបមក សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះសាលាដំបូងប្រកាស ភាពមិនអាចទទួលយកបាននៃសារណាបន្ថែមនេះ ។

**ខ. អំណះអំណាងទីពីរ (មូលដ្ឋានបន្ទាប់បន្សំ)÷ ការឆ្លើយតបទៅលើអង្គសេចក្តី÷**

**១. អំពីគោលការណ៍គ្មានការកាត់ទោសពីរដងលើបទល្មើសតែមួយ៖**

១៨. យើងអាចកត់សម្គាល់ឃើញថា គោលការណ៍គ្មានការកាត់ទោសពីរចំពោះបទល្មើសតែមួយត្រូវបានលើកយកមកពិភាក្សា ហើយសេចក្តីសម្រេចជាច្រើនត្រូវបានចេញដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ជាសេចក្តីសម្រេចដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រក្នុងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។

១៩. ទាក់ទងនឹងការប្រកាសពីពិរុទ្ធភាពត្រួតគ្នាចំពោះអង្គហេតុតែមួយដែលមេធាវីការពារក្តីបានលើកឡើង សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមរំលឹកថា នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ សហចៅក្រមស៊ើប អង្កេត (ស.ច.ស) បានពិចារណាឃើញថា នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គោលការណ៍នេះមិនមានតម្លៃអនុវត្តដាច់ខាតនោះទេ[14]។ ស.ច.ស ក៏បានលើកឡើងផងដែរនូវករណីយុត្តិសាស្ត្ររបស់បណ្តាតុលាការអន្តរជាតិ ទាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិនូវលទ្ធភាពក្នុងការប្រកាសពីពិរុទ្ធភាពត្រួតគ្នាចំពោះអង្គហេតុតែមួយ (cumul de déclarationsde culpabilité) ក្នុងលក្ខខណ្ឌ ដែលបទល្មើសនីមួយៗមានធាតុផ្សំខុស

[13] ឯកសារលេខ E51/11 កថាខណ្ឌទី២៩។

[14] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឯកសារលេខ C22 កថាខណ្ឌ៨, សូមមើលផងដែរនូវសាលក្រមសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សំណុំរឿងលេខ IT-96-21-A ព្រះរាជអាជ្ញា ប្រឆាំងនឹង Delalic et Consorts ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ៤១២។

គ្នាច្បាស់លាស់ដែលបទល្មើសមួយទៀតគ្មាន[15]។ ដូច្នេះ គោលការណ៍នេះមិនរារាំងការចោទប្រកាន់លើ អៀង សារី ក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ។

២០. អង្គបុរេជំនុំជម្រះ បានបញ្ជាក់បន្ថែមជាថ្មីម្តងទៀតនៅក្នុងសាលដីកានេះថា អ.វ.ត.ក ជាតុលាការមួយដែលមានចរិតអន្តរជាតិ មានដំណើរការខុសពីរចនាសម្ព័ន្ធតុលាការកម្ពុជា[16]។ ចំណោទនេះមិនគួរត្រូវបានលើកមកពិចារណាសារជាថ្មី ដោយ អ.ជ.ជ ទេ ព្រោះភាគីបានលើកបង្ហាញជាច្រើនលើកច្រើនសារ ហើយអង្គជំនុំជម្រះនៃ អ.វ.ត.ក ក៏បានធ្វើសេចក្តីសម្រេចយ៉ាងច្បាស់ ពីបញ្ហានេះជាច្រើនដងរួចមកហើយដែរ។

២១. យោងតាមមាត្រា១៤(៧) នៃកតិកាសញ្ញា ICCPR ចែងថា៖

> *«គ្មាន នរណាម្នាក់ត្រូវបានចោទប្រកាន់ឬដាក់ទណ្ឌកម្មដោយហេតុផលថាបទល្មើសមួយដែលគាត់ត្រូវបានដោះលែង ឬ ផ្តន្ទាទោសតាមរយៈសាលក្រមស្ថាពរ ដោយអនុលោម តាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសជាទីមួយ»*[17]។

២២. អ.ប.ជ នៅក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយបានសម្រេចថា ការចោទប្រកាន់ ការជំនុំជម្រះ និងការផ្តន្ទាទោស អៀង សារី ក្នុងឆ្នាំ១៩៧៩ ដោយតុលាការប្រជាជនបដិវត្តន៍មិនរារាំងដល់ការអនុវត្តយុត្តាធិការរបស់ អ.វ.ត.ក ទៅលើ លោក អៀង សារី ឬទៅលើបទចោទណាមួយនៅក្នុងដីកាដំណោះស្រាយនោះទេ[18] ដោយ

---

[15] *ដើងទំព័រដូចគ្នា* កថាខណ្ឌ៩

[16] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារលេខ D427/1/30 កថាខណ្ឌទី១៣១, សូមមើលផងដែរនូវ សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ឌុច ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៧ ឯកសារលេខ C5/45 កថាខណ្ឌ១៨ ដល់២០ សាលដីកាលើបណ្តឹងរបស់មេធាវីការពារក្តី លោក នួន ជា ប្តឹងមិនចិត្តចៅក្រម ន័យ ធុល ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារលេខ C11/29 កថាខណ្ឌ៣០, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តីឌុច (០០១/១៨-០៧-២០០៧/អវតក/អជជ) ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារលេខ E188 កថាខណ្ឌ26 ដល់34, ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ឯកសារលេខ D427 កថាខណ្ឌ១៣០១ ដល់១៣០៧។

[17] មាត្រា១៤នៃកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងសិទ្ធិប្រជាពលរដ្ឋនិងនយោបាយ

[18] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារលេខ D427/1/30 កថាខណ្ឌ១៧៥។

មូលហេតុថា បទដ្ឋាននីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ បានកំណត់ថា គោលការណ៍គ្មានការកាត់ ទោសពីរដងចំពោះបទល្មើសតែមួយនេះ មិនត្រូវបានអនុវត្តក្នុងករណីដូចខាងក្រោម៖

- ដំណើរការសំណុំរឿង មិនគោរពតាមវិធាននានា នៃការកាត់ក្តីប្រកបដោយសមធម៌។
- ដំណើរការសំណុំរឿង មានគោលបំណងធ្វើឱ្យជនដែលពាក់ពន្ធ័នោះ រួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ។
- ដំណើរសំណុំរឿងមិនស្របនឹងបទដ្ឋានឬស្តង់ដារអន្តរជាតិនៃរឿងក្តី[19]។

ដូចគ្នានេះដែរ មាត្រា៤(២)នៃពិធីសារលេខ៧អនុសញ្ញាការពារសិទ្ធិមនុស្សនិងសេរីភាព ជាមូលដ្ឋានចែងជាសារវន្តថា អាចនាំឱ្យមានការសើរើឡើងវិញពីការពិភាក្សាដោយអនុលោមតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនៃសំណុំរឿងប្រសិនបើមានអង្គហេតុថ្មី ការដឹងជាថ្មី ឬវិការៈ ជាមូលដ្ឋានក្នុងនីតិវិធីមុន ដែលជាប្រភពជះឥទ្ធិពលលើសាលក្រមដែលបានសម្រេចរួចហើយ[20]។

**២. អំពីការជម្រះក្តីឆ្នាំ១៩៧៩៖**

២៣. ករណីលើកលែងនេះ ត្រូវបានអនុវត្តដោយតុលាការអន្តរជាតិជាច្រើន ដោយអនុលោមទៅតាមលក្ខន្តិកៈរបស់តុលាការទាំងនោះ[21]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រថា អង្គជំនុំជម្រះត្រូវស្វែងរកការណែនាំនៅក្នុងបទដ្ឋាននីតិវិធី ដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាដែលកំពុងកើតឡើងចំពោះមុខខ្លួន ដែលជាបញ្ហាស្រដៀងគ្នាទៅនឹងបញ្ហាដែលបានកើតឡើងនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតដែរ[22]។

---

[19] អង់តូនីញ៉ូ កាសស៊ីស, នីតិព្រហ្មទណ្ឌអន្តរជាតិ, ការផ្សាយរបស់សាកលវិទ្យាល័យអក់ហ្វត,២០០៣, ទំព័រ១៩-៣២១

[20] មាត្រា៤(២)នៃពិធីសារលេខ៧ អនុសញ្ញាការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន

[21] សូមមើលមាត្រា១០(2)(b) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, មាត្រា៩(២)(b) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាវ៉ាន់ដា និងមាត្រា២០(៣) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ។

[22] ឧទាហរណ៍ករណី សាលក្រមសាលាឧទ្ធរណ៍របស់ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សំណុំរឿងលេខ IT-96-21-A ព្រះរាជអាជ្ញា ប្រឆាំងនឹង Delalic et Consorts ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១, រឿងក្តី រដ្ឋអាជ្ញាតទល់នឹង Tadic, IT-94-1-T សេចក្តីសម្រេចទៅលើសារណារបស់មេធាវីការពារក្តី អំពីគោលការណ៍គ្មានការកាត់ទោសពីរដងលើបទល្មើសតែមួយ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

២៤. លក្ខខណ្ឌនៃអនាគតិ ឯករាជ្យភាព ឬដំណើរការក្តីប្រកបដោយសមធម៌នៃការជម្រះក្តីដែលមិនត្រូវបានធានានៅក្នុងដំណើរការនីតិវិធី នៅចំពោះមុខតុលាការជាតិ គឺជាលក្ខខណ្ឌដែល គោលការណ៍គ្មានការកាត់ទោសពីរដងលើបទល្មើសតែមួយ មិនអាចរារាំងការជម្រះក្តីជាបន្តបន្ទាប់នៅចំពោះមុខតុលាការអន្តរជាតិ[23]។ សំណួរសួរថា តើអ្វីជាលក្ខខណ្ឌតម្រូវ ដើម្បីឱ្យតុលាការមួយមានឯករាជ្យភាព និងអនាគតិ? ដើម្បីអាចពិចារណាលើឯករាជ្យភាពរបស់តុលាការមួយ តុលាការសិទ្ធិមនុស្សសហគមន៍អឺរ៉ុបនឹងពិនិត្យមើលលើ ការចាត់តាំងសមាជិករបស់តុលាការ (ចៅក្រម ព្រះរាជអាជ្ញា មេធាវី ...) រយៈពេលនៃការប្រកបមុខងាររបស់ពួកគេ អត្ថិភាពនៃការធានាប្រឆាំងនឹងសម្ពាធពីមជ្ឈដ្ឋានខាងក្រៅ ... [24]។ ការជម្រះក្តីប្រកបដោយសមធម៌ ទាមទារឱ្យមានការគោរពវិធាននីតិវិធីឱ្យបានត្រឹមត្រូវ ទាក់ទងនឹងឧទាហរណ៍ដូចជា រយៈពេលនៃការស៊ើបអង្កេត និងសវនការ ស្តង់ដានៃការស្តាប់ចម្លើយសាក្សី វិធាននៃភស្តុតាង ...។ កត្តាទាំងនេះ គឺជាចំណុចដែលត្រូវវិភាគ ដើម្បីធ្វើការវិនិច្ឆ័យថា ការជម្រះក្តីមួយប្រកបសមធម៌ឬទេ។

២៥. ដោយមូលហេតុថា បទដ្ឋាននីតិវិធីដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ មានអានុភាពអនុវត្តនៅចំពោះមុខ អ.វ.ត.ក ការវិភាគលើកម្រិតនៃការគោរពបទដ្ឋានត្រឹមត្រូវនៃនីតិវិធីនៃការជម្រះក្តីឆ្នាំ១៩៧៩ មានលក្ខណៈចាំបាច់ ដើម្បីអាចសម្រេចបានថា ការជម្រះក្តីនេះ អាចរារាំងការចោទប្រកាន់លោក អៀង សារី នាពេលបច្ចុប្បន្ននេះឬទេ។

២៦. នៅក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ លោក អៀង សារីប្រឆាំងនឹងដីកាដំណោះស្រាយ អង្គជំនុំបុរេជំនុំជម្រះបានធ្វើការវិភាគយ៉ាងល្អិតល្អន់ និងគ្រប់ជ្រុងជ្រោយលើការជម្រះក្តីឆ្នាំ១៩៧៩នេះ[25]។ អង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងត្រឹមត្រូវថា ការកាត់សេចក្តីឆ្នាំ១៩៧៩ មិន

---

[23] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារលេខ D427/1/30 កថាខណ្ឌ១៤៤ ដល់ ១៤៦។

[24] សូមមើលសៀវភៅ Human Rights Handbook No.3, The Rights to a Fair Trial, Aguide to implementation of Article 6 of the European Convention on Human Rights, by Nuala Mole and Catharina Harby ទំព័រ៣០ ដល់ ៣៨។

[25] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារលេខ D427/1/30 កថាខណ្ឌ១៦១ ដល់ ១៧៦។

បានប្រព្រឹត្តិទៅដោយឯករាជ្យ និងអនាគតិ ស្របតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋាន នីតិវិធីនោះទេ[26]។

២៧. អំណាននៃសារណាបន្ថែមរបស់មេធាវីការពារក្តី ហាក់ដូចជាបង្ហាញថា មេធាវីការពារក្តីបានទទួលស្គាល់នូវរាល់កំហុសឆ្គងនៃការជម្រះក្តីឆ្នាំ១៩៧៩ ដូចការវិភាគរបស់អង្គបុរេជំនុំជម្រះ[27]។

**IV- សេចក្តីសន្និដ្ឋាន**

២៨. ដោយឈរលើអំណះអំណាងនៃហេតុផលខាងលើ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា៖

អង្គជំនុំជម្រះសាលាដំបូង

1) ប្រកាសថាសារណាបន្ថែមនេះ មិនអាចទទួលយកបានឡើយ
2) ប្រកាសច្រានចោលគ្រប់ទឡ្ហីករណ៍របស់មេធាវីការពារក្តីដោយមូលហេតុមិនត្រឹមត្រូវតាមគតិច្បាប់ ក្នុងករណីដែល អ.ប.ដ សម្រេចពិចារណាលើសារណាបន្ថែមនេះ ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ០៦ មិថុនា ២០១១ | **ពេជ អន្ទ**<br>សហមេធាវីនាំមុខជាតិ | ភ្នំពេញ | [signature] |
| | Elisabeth Simonneau-Fort<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | [signature] |
| | **ម៉ុច សុវណ្ណារី**<br>សហមេធាវីជាតិ | ភ្នំពេញ | [signature] |
| | **គឹម ម៉េងឃី**<br>សហមេធាវីជាតិ | ភ្នំពេញ | [signature] |
| | Fabienne TRUSSES NAPROUS<br>សហមេធាវីអន្តរជាតិ | ភ្នំពេញ | [signature] |

[26] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៧៥។

[27] ឯកសារ E51/11 កថាខណ្ឌ៣០។